01631665



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 11 / 2019
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

**សំណុំរឿង ០០៣/០៧០-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥)**

## របាយការណ៍នៃសំណុំរឿង និងបណ្តឹងឧទ្ធរណ៍

I- សេចក្តីផ្តើម
II- ការកំណត់អត្តសញ្ញាណជនត្រូវចោទ
III- សាវតារសំណុំរឿង
IV- ដីកាដំណោះស្រាយដែលស្ថិតក្រោមបណ្តឹងឧទ្ធរណ៍
V- ទិដ្ឋភាពទូទៅនៃកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ និងបញ្ហានានាដែលបានលើកឡើង
VI- សេចក្តីសន្និដ្ឋាន

### I- សេចក្តីផ្តើម

របាយការណ៍នេះត្រូវបានធ្វើឡើងក្នុងនាមអង្គបុរេជំនុំជម្រះទាំងមូល។ របាយការណ៍នេះបង្ហាញពីប្រវត្តិនីតិវិធី និងអង្គហេតុពាក់ព័ន្ធ នៅក្នុងសំណុំរឿង ០០៣ ព្រមទាំងព័ត៌មានលម្អិតនៃបណ្តឹងឧទ្ធរណ៍ដែលមាននៅចំពោះមុខអង្គបុរេជំនុំជម្រះនាពេលនេះ។

### II- ការកំណត់អត្តសញ្ញាណជនត្រូវចោទ

ជនត្រូវចោទមានឈ្មោះ មាស មុត ភេទប្រុស សញ្ជាតិកម្ពុជា កើតនៅថ្ងៃទី១០ ខែសីហា ឆ្នាំ ១៩៣៨ នៅភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្នគាត់មានទីលំនៅនៅក្នុងខេត្តបាត់

ដំបង[1]។ បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញដីកាកំណត់កាលវិភាគសម្រាប់សវនាការ ដោយបង្គាប់ *ក្នុងចំណោមប្រការផ្សេងទៀត* ថា សំណើបញ្ជាក់ពីភាពមិនចាំបាច់នៃការចូលបង្ហាញខ្លួនផ្ទាល់របស់ជនត្រូវចោទ ត្រូវដាក់ជូនអង្គជំនុំជម្រះដោយបង្ហាញយុត្តិកម្មឱ្យបានពេញលេញ[2] អង្គបុរេជំនុំជម្រះក៏បានទទួលយកសំណើរបស់ មាស មុត[3] ដោយអនុញ្ញាតឱ្យគាត់មិនចូលបង្ហាញខ្លួនផ្ទាល់នៅពេលសវនាការទេ ដោយសារហេតុផលសុខភាព[4]។

មាស មុត ត្រូវបានតំណាងដោយមេធាវី លោក អាង ឧត្តម និង លោក Michael KARNAVAS ("សហមេធាវីការពារក្តី")។

## III- សាវតារសំណុំរឿង

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិបានចុះហត្ថលេខាទៅលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ដោយចោទប្រកាន់ ស៊ូ ម៉េត និង មាស មុត ថាទទួលខុសត្រូវលើឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក[5]។ នៅថ្ងៃដដែលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ ដោយលើកឡើងថា សហព្រះរាជអាជ្ញាជាតិ មិនយល់ស្របជាមួយការចោទប្រកាន់លើឧក្រិដ្ឋកម្មដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានថ្មីឡើយ[6]។ អង្គបុរេជំនុំជម្រះបានចេញការពិចារណាទៅលើការខ្វែង

---

1 [redacted]

2 សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") ដីកាកំណត់កាលវិភាគសម្រាប់សវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៩ ឯកសារ D266/12 និង D267/17 ទំព័រ ២។

3 សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំអនុញ្ញាតមិនចូលបង្ហាញខ្លួនផ្ទាល់ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/13 និង D267/18។

4 សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអនុញ្ញាតមិនចូលបង្ហាញខ្លួនផ្ទាល់ក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ឯកសារ D266/14 និង D267/19។

5 សំណុំរឿង ០០៣/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៣") ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តកម្ពុជា 20 ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ ឯកសារ D1.

6 ការខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អបជ ឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(២) ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ No. 1។

យោបល់គ្នានេះ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩[7]។

នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[8] ហើយបន្ទាប់មក នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[9] ដោយស្នើដល់សហចៅក្រមស៊ើបអង្កេតឱ្យបើក និងបំពេញកិច្ចស៊ើបសួរ ទៅលើ ស៊ូ ម៉េត និង មាស មុត ទាក់ទងនឹងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានទៅលើ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅតាមទីកន្លែងផ្សេងៗគ្នា ដូចជា ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខ ស-២២ ទីតាំងសម្លាប់មនុស្សស្ទឹងតូច ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងមន្ទីរសន្តិសុខដទៃទៀត ដែលដំណើរការដោយកងពលធំនៃកងទ័ពបដិវត្តកម្ពុជា។ ការខ្វែងយោបល់គ្នាជាសម្ងាត់រវាងសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងកិច្ចស៊ើបអង្កេតនេះ ត្រូវបានចុះកំណត់ហេតុនៅថ្ងៃទី៧ និងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១៨។ មិនមានការប្តឹងអំពីការខ្វែងយោបល់ណាមួយមកអង្គបុរេជំនុំជម្រះឡើយ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ដោយជូនដំណឹងដល់ភាគីថា សហចៅក្រមស៊ើបអង្កេតពិចារណាថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់[10]។

នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានចាប់ផ្តើមកិច្ចស៊ើបសួរតាមផ្លូវតុលាការឡើងវិញ[11]។

---

[7] ការខ្វែងយោបល់គ្នា ០០១/១៨-១១-២០០៨-អវតក/អបជ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3។

[8] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[9] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានា ទាក់ទងនឹងសំណុំរឿង ០០៣ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120។

[10] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13។

[11] សំណុំរឿង ០០៣ ដីកាសម្រេចស្តីអំពី ការបើកការស៊ើបអង្កេតបឋមឡើងវិញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។

នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានជូនដំណឹងទៅ ស៊ូ ម៉េត និង មាស មុត ថា ពួកគាត់គឺជាជនសង្ស័យ ហើយបានជូនដំណឹងអំពីសិទ្ធិរបស់ពួកគាត់[12]។

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា ដោយអញ្ជើញសហព្រះរាជអាជ្ញា ឱ្យដាក់ដីកាសន្និដ្ឋានស្ថាពរ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[13]។ នៅថ្ងៃដដែលនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចុះហត្ថលេខាលើដីកាចាត់ឱ្យស៊ើបសួរជំនួស ដោយបង្គាប់ឱ្យអ្នកស៊ើបអង្កេតអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បំពេញកិច្ចស៊ើបសួរ[14]។ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយលើកមតិថា ការស៊ើបអង្កេតនៅកំពុងតែបន្ត ហើយបង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតវិញ[15]។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ជាក់ថា គាត់ចាត់ទុកចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ថាជាដីកាសន្និដ្ឋានស្ថាពរ ចំណែកសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ថា សំណុំរឿង០០៣ នៅកំពុងបន្តដំណើរការ ហើយការស៊ើបអង្កេតលើអង្គហេតុ ដែលត្រូវបានចោទប្រកាន់ក្នុងសំណុំរឿង កំពុងតែបន្តដំណើរការ[16]។

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ស៊ូ ម៉េត បានស្លាប់[17] ហើយបានបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់ នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥[18]។

---

[12] សំណុំរឿង ០០៣ ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ វិធាន ២១.១ ឃ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ [ពាក់ព័ន្ធ មាស មុត] ឯកសារ D30។ សំណុំរឿង ០០៣ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ វិធាន ២១.១ ឃ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ [ពាក់ព័ន្ធ ស៊ូ ម៉េត] ឯកសារ D31។

[13] សំណុំរឿង ០០៣ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D52។

[14] សំណុំរឿង ០០៣ ដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D54។

[15] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ D52/1។

[16] សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសំណុំរឿង ០០៣ https://www.eccc.gov.kh/en/articles/statement-co-investigating-judges-regarding-case-003។

[17] សំណុំរឿង ០០៣ ការជូនដំណឹងអំពីការស្លាប់របស់ជនសង្ស័យម្នាក់នៅ ក្នុងសំណុំរឿង ០០៣ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ឯកសារ D86។

[18] សំណុំរឿង ០០៣ ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3។

នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកោះហៅ មាស មុត ឱ្យមកបង្ហាញខ្លួនជាលើកដំបូងនៅ អ.វ.ត.ក ដោយកំណត់យកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤[19]។ ដីកាកោះហៅត្រូវបានសហមេធាវីការពារក្តីជំទាស់[20] ហើយនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ អង្គបុរេជំនុំជម្រះបានទទួលស្គាល់អំពីសុពលភាពនៃដីកាកោះហៅ[21]។ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ក្រោយពេលដែលគាត់មិនបានបង្ហាញខ្លួន[22]។

នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[23] ហើយបានរៀបរាប់លម្អិតអំពីបទចោទនៅក្នុងឧបសម្ព័ន្ធនៃដីកាសម្រេច[24] ហើយសហមេធាវីការពារក្តីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ នៅថ្ងៃទី១២[25] និងថ្ងៃទី១៦[26] ខែមិថុនា ឆ្នាំ២០១៥។ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ និងសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦[27]។

---

[19] សំណុំរឿង ០០៣ ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ A66។

[20] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ A67/1.1។

[21] សំណុំរឿង ០០៣ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ D117/1/1/2។

[22] សំណុំរឿង ០០៣ ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ និងដាក់ចូលសំណុំរឿង ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ C1។

[23] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។

[24] សំណុំរឿង ០០៣ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១៥ ឯកសារ D128.1។

[25] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128.1/1/3។

[26] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D128/1/3។

[27] សំណុំរឿង ០០៣ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំង មាស មុត ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ [redacted]។ សំណុំរឿង ០០៣

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នៅពេលបង្ហាញខ្លួនជាលើកដំបូងរបស់ មាស មុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញបទចោទមួយចំនួនប្រឆាំងនឹង មាស មុត ហើយបានចោទប្រកាន់គាត់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើមនុស្សឃាតដោយគិតទុកមុន[28] ដែលបានប្រព្រឹត្តចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅក្នុងអតីតតួនាទីរបស់គាត់ជាសមាជិកអគ្គសេនាធិការយោធា ជាមេបញ្ជាការកងពលធំ ១៦៤ (រួមបញ្ចូលទាំងកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ) និងសិទ្ធិអំណាចខ្ពស់បំផុតខាងផ្នែកស៊ីវិល នៅតំបន់ស្វយ័តកំពង់សោម។ មាស មុត ត្រូវបានចោទប្រកាន់តាមរយៈទម្រង់នៃការទទួលខុសត្រូវខុសៗគ្នា ដូចជា ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ការរៀបចំផែនការ ការបញ្ជា ការទទួលខុសត្រូវរបស់ថ្នាក់លើ និងសហចារីកម្ម[29]។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេត ដោយដកចេញបទចោទទាក់ទងនឹងមន្ទីរសន្តិសុខ ស-២២ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ទីតាំងសម្លាប់មនុស្សស្ទឹងតូច និងការចូលរួមរបស់កងទ័ពបដិវត្តកម្ពុជានៅក្នុងការបោសសម្អាតភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា[30]។ ហេតុដូច្នេះ អង្គហេតុដែលបានដកចេញទាំងអស់នេះ លែងជាមូលដ្ឋានសម្រាប់បទចោទណាមួយប្រឆាំង មាស មុត ទៀតហើយ[31]។

នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីជូន

---

សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ឯកសារ D128/1/9។

[28] សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។

[29] ទោះបីយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ មាស មុត ថាត្រូវតែបង្ហាញខ្លួនតាមតម្រូវការរបស់ អ.វ.ត.ក។ មាស មុត ក៏បានប្រកាសថាគាត់ស្ម័គ្រចិត្តទទួលការចុះត្រួតពិនិត្យប្រចាំសប្តាហ៍ពីនគរបាលនៅគេហដ្ឋានរបស់គាត់ ហើយថាគាត់មានតែលិខិតឆ្លងដែនដែលផុតសុពលភាព ៥ ឆ្នាំ ទៅហើយ។ មាស មុត បញ្ជាក់ទៀតថា គាត់ ឬមេធាវីរបស់គាត់នឹងជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត នៅពេលដែលគាត់មានបំណងចាកចេញទៅក្រៅប្រទេសដើម្បីព្យាបាលសុខភាព (សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174 ទំព័រ ១៧)។

[30] សំណុំរឿង ០០៣ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226។

[31] វិធាន ៦៦ ស្ទួន (៥) នៃវិធានផ្ទៃក្នុង។

ដំណឹងជាលើកទីពី ស្តីពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំង មាស មុត[32] ហើយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០១៧ បានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា ដោយស្នើឲ្យសហព្រះរាជអាជ្ញា ចេញដីកាសន្និដ្ឋានស្ថាពរ នៅក្នុងរយៈពេលបីខែ[33]។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ដោយស្នើសុំឲ្យលើកលែងការចោទប្រកាន់ទាំងអស់ ផ្អែកលើមូលដ្ឋានថា មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[34]។ នៅថ្ងៃដដែលនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឲ្យចោទប្រកាន់ មាស មុត ពីបទចោទនានា ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងបញ្ជូនទៅជំនុំជម្រះ[35]។

## IV- ដីកាដំណោះស្រាយដែលស្ថិតក្រោមបណ្តឹងឧទ្ធរណ៍

### ក. សេចក្តីផ្តើម

អនុលោមតាមវិធាន ៦៧ នៃវិធានផ្ទៃក្នុង "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់"[36]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែ "បញ្ជាក់អំពីអត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស ដោយសហចៅក្រមស៊ើបអង្កេត ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[37]។ "សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់" ក្នុងករណី ក-អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ខ-ជនប្រព្រឹត្តបទឧក្រិដ្ឋនោះមិនទាន់

---

[32] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងទី២ ស្តីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D252។

[33] សំណុំរឿង ០០៣ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ យោងតាមវិធានផ្ទៃក្នុង ៦៦(៤) ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D256។

[34] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D256/6។

[35] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/7។

[36] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង។

[37] វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។

ត្រូវបានកំណត់អត្តសញ្ញាណនៅឡើយ ឬ គ-ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ[38]។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ពួកគាត់បានពិចារណាដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ដោយផ្អែកលើការខ្វែងយោបល់របស់ពួកគេដែលត្រូវបានអនុញ្ញាតដោយច្បាប់ជាធរមាន[39]។ សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ហេតុការខ្វែងយោបល់គ្នាទាក់ទងនឹងការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ដោយការខ្វែងយោបល់គ្នានេះ មិនត្រូវបានបញ្ជូនមកអង្គបុរេជំនុំជម្រះឡើយ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយបញ្ជូន មាស មុត ទៅជំនុំជម្រះ[40] ចំណែកសហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងការចោទប្រកាន់) ដោយលើកលែងរាល់បទចោទប្រកាន់ទាំងអស់ប្រឆាំងនឹង មាស មុត[41]។ ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា នៅក្នុងសំណុំរឿងតែមួយ ក៏កើតឡើងផងដែរនៅក្នុងសំណុំរឿងប្រឆាំងនឹង អោ អាន និង យឹម ទិត្យ។ អង្គបុរេជំនុំជម្រះមិនទាន់បានសម្រេចថាតើ ការអនុវត្តបែបនេះអាចត្រូវបានអនុញ្ញាតបានដែរឬទេតាមច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក នោះ។

នាពេលនេះយើងនឹងផ្តល់ទិដ្ឋភាពរួមសង្ខេបនៃការសម្រេចជាចម្បងរបស់ដីកាដំណោះស្រាយនីមួយៗ ដែលបានចេញនៅក្នុងសំណុំរឿងនេះ។

### ខ. ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)

---

[38] វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង។

[39] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262។ សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធ នឹងការខ្វែងយោបល់ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D262.2 កថាខណ្ឌ ១៣ -១៦។

[40] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ("ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267)").

[41] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ("ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266)")

នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណា និងវិភាគទៅលើភស្តុតាងទាក់ទងនឹងការចោទប្រកាន់ចំពោះរចនាសម្ព័ន្ធកងទ័ពបដិវត្តកម្ពុជា[42] អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម[43] ជម្លោះប្រដាប់អាវុធជាមួយវៀតណាម និងថៃ[44] ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[45] និងនៅទីតាំងសម្លាប់មនុស្សចំការទុរេន[46] ប្រឆាំងចំពោះសមាជិកនៃកងពលធំ ១៦៤, ៥០២, ១១៧ និង៣១០ នៃកងទ័ពបដិវត្តកម្ពុជា[47] នៅតំបន់រាម[48] ការដ្ឋានស្ទឹងហាវ[49] មន្ទីរសន្តិសុខទឹកសាប[50] និងវត្តឥន្ទញាណ[51] និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម[52] ដោយពាក់ព័ន្ធនឹងការបង្ហាញនានាអំពីតួនាទី និងការចូលរួមរបស់ មាស មុត នៅក្នុងនោះ។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា តួនាទី និងការទទួលខុសត្រូវរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញថា គាត់មានភាពជិតស្និទ្ធខ្លាំងជាមួយកម្រិតដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា[53]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចថា តួនាទីរបស់ មាស មុត

---

[42] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ១៩៩ -១៧០។

[43] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ១៧១ -២០៥។

[44] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ២០៦ -២១៦។

[45] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ២១៧ -២៥៧។

[46] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ២៥៨ -២៦៩។

[47] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ២៧០ -៣២៩។

[48] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៣៣០ -៣៥៤។

[49] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៣៥៥ -៤០២។

[50] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤០៣ -៤២៥។

[51] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤២៦ -៤៤៣។

[52] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៤៤ -៤៥៥។

[53] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៣២ -៣៧, ៤៥៩។ *សូមមើល ផងដែរ* ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)(ឯកសារ D267) ដែលកំណត់ថា តួនាទី និងការទទួលខុសត្រូវរបស់ មាស មុតរួមមាន៖ (១) ជាមេបញ្ជាការកងពលធំ១៦៤ (កងពលធំជាងគេបំផុតនៃកងទ័ពបដិវត្តកម្ពុជា ដែលពីមុនជាកងពលធំលេខ៣) នៅមុនខែមេសា ឆ្នាំ១៩៧៥ ដែលជាតួនាទីជាមេបញ្ជាការកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ (ជាផ្នែកមួយក្នុងចំណោមផ្នែកទាំងបីនៃកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យ) (កថាខណ្ឌ ១៥៦, ១៥៨, ៤៥៩(i)) (២) ទទួលខុសត្រូវលើដែនទឹក ដែលរបបកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន (កថាខណ្ឌ ១៥៨, ៤៥៩(ii)) (៣) ជាសមាជិកបម្រុងរបស់គណៈកម្មាធិការអគ្គសេនាធិការ និងជាអនុប្រធានមួយរូបរបស់ សុន សេន (កថាខណ្ឌ ១៦២, ៤៥៩(iii) និង (៤) ចាប់ពីចុងឆ្នាំ១៩៧៨ ជាសមាជិកបម្រុងរបស់គណៈកម្មាធិការមជ្ឈិម (កថាខណ្ឌ ១៦២, ៤៥៩(iv))។

នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ មានន័យថា គាត់ត្រូវបំពេញការងារនៅ "កម្រិតខ្ពស់បំផុតនៅក្នុងរចនាសម្ព័ន្ធបញ្ជាការកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមការដឹកនាំរបស់អ្នកនយោបាយថ្នាក់ជាតិ" ហើយទទួលភារកិច្ចបន្ថែមទៀតលើការអនុវត្តការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា លើសពីតំបន់កំពង់សោម និងភារកិច្ចរបស់គាត់ជាមេបញ្ជាការកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[54]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចបន្ថែមទៀតថា ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ មាស មុត, សុន សេន, ស៊ូ ម៉េត, តាម៉ុក និងកម្មាភិបាលកងទ័ពបដិវត្តកម្ពុជាជាន់ខ្ពស់ដទៃទៀត មានគោលបំណងរួមគ្នា ក្នុងការអនុវត្តគោលនយោបាយទាំងបួនរបស់បក្សកុម្មុយនីស្តកម្ពុជា[55] នៅក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ តំបន់ស្វយ័តកំពង់សោម និងទីតាំងដទៃផ្សេងៗនៅក្នុងកម្ពុជាប្រជាធិបតេយ្យ តាមរយៈការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានអនុវត្តតាមរយៈសហឧក្រិដ្ឋកម្មរួម[56] ដែល មាស មុត គឺជាអ្នកចូលរួមប្រកបដោយឆន្ទៈស្រួចស្រាល់[57] និងតាមរយៈការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ តាមរយៈសហចារី និងការរៀបចំផែនការ និងការបញ្ជា[58]។

នៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

[54] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦១។

[55] គោលនយោបាយទាំងបួនរបស់ ប.ក.ក រួមមាន (១) ការបង្កើតសហករណ៍ និងការដ្ឋានពលកម្មដោយបង្ខំ (២) ការអប់រំ "សមាសធាតុមិនល្អ" និង "ការសម្លាប់ខ្មាំង" ទាំងក្នុង និងក្រៅជួរយោធា (៣) ការកំណត់មុខសញ្ញាក្រុមជាក់លាក់ ជាពិសេសអ្នកទាំងឡាយណាដែលជាជនជាតិភាគតិច ឬជនជាតិ វៀតណាម និងថៃ (ទាំងពិតប្រាកដ និងតាមការសន្មត) ព្រមទាំងអតីតបុគ្គលិកយោធា និងប្រជាជនស៊ីវិល (៤) ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ លើប្រជាជនស៊ីវិលនិងយោធានៃកងទ័ពបដិវត្តន៍កម្ពុជា។ សូមមើល ផងដែរ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ១៧១, ៥៦២។

[56] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦២-៤៦៦, ៥៦២។

[57] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦១, ៤៦៩។

[58] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៥៧៦, ៥៧៧។

បានប្រើវិធីសាស្ត្រ "ចំនួនជនរងគ្រោះអប្បបរមា ដែលអាចធ្វើការប៉ាន់ស្មានបាន តាមរយៈភស្តុតាង"[59] នៅពេលវាយតម្លៃពីចំនួនជនរងគ្រោះនៅក្នុងឧក្រិដ្ឋកម្មនីមួយៗ។ យ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់ថា ចំនួនជនរងគ្រោះជាក់ស្តែង អាចមានលទ្ធភាពខ្ពស់ដែលថា មានចំនួនច្រើនជាងឆ្ងាយពីចំនួនប៉ាន់ស្មាននេះ[60]។ លោកចៅក្រមបានដាក់បន្ទុកផងដែរទៅលើ មាស មុត ចំពោះចំនួនជនរងគ្រោះជាជនជាតិថៃ យ៉ាងតិចបំផុត ១.២០០នាក់ និងជនជាតិវៀតណាមយ៉ាងតិចបំផុត ៣២៧៦ នាក់ ដែលត្រូវបានសម្លាប់ នៅក្នុងអំឡុងប្រតិបត្តិការចាប់ខ្លួនពីសំណាក់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[61] និងជនរងគ្រោះចំនួន ២១៥២នាក់ ទាក់ទងនឹងការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា[62] និងជនរងគ្រោះចំនួន ៨៤៥នាក់ ដែលត្រូវបានសម្លាប់នៅទីតាំងឧក្រិដ្ឋកម្មកំពង់សោម[63]។ លោកចៅក្រមយល់ថា យ៉ាងតិចបំផុត ២០០០ នាក់នៅការដ្ឋានតំបន់រាម និង ១០០ នាក់នៅស្ទឹងហាវ ក្នុងពេលណាមួយ គឺជាជនរងគ្រោះនៃពលកម្មដោយបង្ខំ[64]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានប៉ាន់ប្រមាណថា មានមនុស្សប្រហែល ១៥០០០ នាក់ ប្រហែលជាត្រូវទទួលរងពលកម្មដោយបង្ខំ ក្រោមស្ថានភាពដ៏អាក្រក់បំផុតនៅតំបន់
កំពង់សោម[65]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើ មាស មុត ក្នុងនាមជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" មួយរូបចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែឋានៈ និងវិសាលភាពនៃសិទ្ធិអំណាចរបស់គាត់នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ រួមជាមួយនឹងលក្ខណៈ និងទំហំនៃឧក្រិដ្ឋកម្មរបស់គាត់[66]។ បន្ទាប់ពីបានពិនិត្យមើលលើភស្តុតាង និងបានសន្និដ្ឋានថា ធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្ម[67] និងទម្រង់នៃការទទួលខុសត្រូវ[68] ត្រូវបានកំណត់រួចមក សហចៅក្រម

[59] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ១៣៣។
[60] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ១៣៣។
[61] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦៤។
[62] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦៧។
[63] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦៨។
[64] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៦៨។
[65] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ៤៦៨។
[66] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៥៦-៤៦៩។
[67] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៧០-៥៦១។
[68] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៥៦២-៥៧៧។

ស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ និងបញ្ជូន មាស មុត ទៅជំនុំជម្រះ ពីបទ៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម ដោយការសម្លាប់សមាជិកក្រុម តាមរយៈការប្រព្រឹត្តិសហឧក្រិដ្ឋកម្មរួម ឬជាជម្រើយមួយផ្សេងទៀត តាមរយៈការរៀបចំផែនការ ឬការបញ្ជា ឬតាមជម្រើសផ្សេងមួយបន្ថែមទៀត តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ។

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ ពូជសាសន៍ ឬនយោបាយ និងអំពើអមនុស្សធម៌ដទៃផ្សេងទៀត (ដូចជា ការបាត់ខ្លួនដោយបង្ខំ ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ) ដែលប្រព្រឹត្តឡើងនៅតាមទីតាំងផ្សេងៗ ដូចជា នៅក្នុងដែនទឹក និងនៅលើកោះនានា ដែលរបបកម្ពុជាប្រជាធិបតេយ្យ អះអាងថាជារបស់ខ្លួន និងនៅក្នុងតំបន់កំពង់សោម, មន្ទីរសន្តិសុខស-២១, ទីតាំងសម្លាប់មនុស្សចំការទុរេន, ការដ្ឋានតំបន់រាម និងស្ទឹងហាវ, មន្ទីរសន្តិសុខទឹកសាប និងវត្តឥន្ទញាណ តាមរយៈការប្រព្រឹត្តិសហឧក្រិដ្ឋកម្មរួម ឬការរៀបចំផែនការ ការបញ្ជា ឬការទទួលខុសត្រូវរបស់ថ្នាក់លើ។

- ឧក្រិដ្ឋកម្មសង្គ្រាម ដូចជា ការរំលោភបំពាន់យ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចជាការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ការសម្លាប់មនុស្សដោយចេតនា ការបង្កដោយចេតនានូវការឈឺចាប់ ឬរបួសស្នាមធ្ងន់ធ្ងរទៅលើរូបរាងកាយ ឬសុខភាព និងបន្ថែមលើនេះនៅមន្ទីរសន្តិសុខស-២១ ការធ្វើទារុណកម្ម ទៅលើជនជាតិវៀតណាម និងជនជាតិថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ដែលប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម ឬជាជម្រើសផ្សេង តាមរយៈការរៀបចំផែនការ ការបញ្ជា ឬជាជម្រើសមួយផ្សេងបន្ថែមទៀត តាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ និង

- អំពើមនុស្សឃាតដោយគិតទុកមុន ដែលរំលោភបំពានទៅលើមាត្រា ៥០១ និង៥០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលបានប្រព្រឹត្តនៅទីតាំងផ្សេងៗគ្នា ដូចជា ទីតាំងសម្លាប់មនុស្សចំការទុរេន, ការដ្ឋានស្ទឹងហាវ និងមន្ទីរសន្តិសុខទឹកសាប និងវត្តឥន្ទញាណ ព្រមទាំងការសម្លាប់ជនជាតិវៀតណាម និងជនជាតិថៃដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងការបោសសម្អាតកងពលធំ ១៦៤, ៥០២, ១១៧ និង៣១០ តាមរយៈការប្រព្រឹត្តិសហចារីកម្ម និង (លើកលែងតែឧក្រិដ្ឋកម្មដែលទាក់ទងនឹង កងពលធំ៥០២ និង៣១០) ជាជម្រើសមួយផ្សេងទៀត ការ

រៀបចំផែនការ ឬការបញ្ជា។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានច្រានចោលបទចោទមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដោយសារតែមិនមានភស្តុតាងគ្រប់គ្រាន់[69]។ លោកចៅក្រមបានយល់ឃើញទៀតថា មិនមានភាពចាំបាច់ក្នុងការឃុំខ្លួន មាស មុត នៅមុនពេលជំនុំជម្រះឡើយ[70]។

**គ. ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)**

នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់លម្អិតអំពីការសម្រេចរបស់គាត់ ទាក់ទងនឹងអង្គហេតុចោទប្រកាន់ប្រឆាំងនឹង មាស មុត ដែលពឹងផ្អែកទៅលើសម្ភារៈដែលបានដាក់ចូលសំណុំរឿង នៅមុនពេលមានសេចក្តីជូនដំណឹងលើកទីមួយ ស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ដែលបានចេញនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១[71] ហើយផ្តោតទៅលើថាតើ មាស មុត គឺជាមេដឹកនាំជាន់ខ្ពស់ ឬស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត យោងតាមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា[72]។ លោកចៅក្រមសម្រេចថា ជាការមិនចាំបាច់ដែលត្រូវរៀបរាប់អំពីប្រភេទនៃឧក្រិដ្ឋកម្ម ការកំណត់ប្រភេទនៃបទចោទ ឬទម្រង់នៃការទទួលខុសត្រូវ ដោយលោកចៅក្រមពិចារណាទៅលើ អង្គហេតុដែលត្រូវបានចោទប្រកាន់ផ្អែកលើលក្ខណវិនិច្ឆ័យចំនួនពីរ គឺ (១) ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និង (២) កម្រិតនៃការចូលរួមរបស់ មាស មុត[73]។ លោកចៅក្រមបានបញ្ជាក់ថា ក្នុងករណីមានវិមតិសង្ស័យ នៅពេលធ្វើការសម្រេចលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក លើ មាស មុត ប្រយោជន៍នឹងត្រូវបានផ្តល់ជូនជនត្រូវចោទ[74]។

សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់ថា គាត់បានស៊ើបអង្កេតទៅលើអង្គហេតុចំនួនប្រាំពីរក្នុង

---

[69] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៤៩៦, ៥១១, ៥១៩, ៥៣៥, ៥៤៩-៥៥០, ៥៨១។

[70] ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) (ឯកសារ D267) កថាខណ្ឌ ៥៧៨-៥៧៩។

[71] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ២-៣, ៣៩, ២៦២។

[72] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣។

[73] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣។

[74] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣។

ចំណោមអង្គហេតុចំនួនដប់ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[75]។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ក៏បានពិចារណាផងដែរអំពីតួនាទី និងសិទ្ធិអំណាចរបស់ មាស មុត នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា រួមទាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម[76] គណៈកម្មាធិការអចិន្ត្រៃយ៍[77] មន្ទីរនយោបាយ និងរដ្ឋាភិបាល[78] ក្រសួង[79] និងកងទ័ពបដិវត្តន៍កម្ពុជា[80] ជាពិសេស កងពលធំ ១៦៤[81]។ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ក៏មានបន្ថែមការសម្រេចលើគោលនយោបាយបោសសម្អាតនៅក្នុងជួរកងទ័ព (រួមទាំងភូមិភាគបូព៌ា) និង ការបង្កើតគោលនយោបាយផ្ទាល់[82] ការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការបោសសម្អាត[83] និងការចូលរួមរបស់ មាស មុត នៅក្នុងការបោសសម្អាត[84]។

ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិ បានសម្រេចផងដែរថា មាស មុត គឺជាលេខាកងពលធំ ១៦៤ ជាលេខាដែលទទួលខុសត្រូវលើ កិច្ចការនយោបាយដែលផ្តោតសំខាន់លើ ការផ្សព្វផ្សាយគោល

[75] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៥៤។ ចៅក្រមបានសម្រេចថា មានតែអង្គហេតុចំនួនប្រាំបីប៉ុណ្ណោះពាក់ព័ន្ធនឹង មាស មុត ចំណែកអង្គហេតុទាក់ទងនឹងការបង្ក្រាបក្នុងកងពលលេខ ៨០១ និងមន្ទីរសន្តិសុខ ៨១០ ជាអង្គហេតុទាក់ទងគ្នា។ ហេតុដូច្នេះ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ផ្តល់ការសម្រេច ទាក់ទងនឹងការចូលរួមដែលត្រូវបានចោទប្រកាន់របស់ មាស មុត នៅក្នុង (១) ការបោសសម្អាតនៅក្នុងកងពលធំ ១៦៤ និងបុគ្គលិកអគ្គសេនាធិការ (កថាខណ្ឌ ២៦៣-២៨៧) (២) មន្ទីរសន្តិសុខវត្តឥន្ទញាណ (កថាខណ្ឌ ២៨៨-២៩៧) (៣) ស្ថានភាពរស់នៅ និងធ្វើការនៅការដ្ឋានវាយថ្មស្ទឹងហាវ (កថាខណ្ឌ២៩៨-៣០៥) (៤) ការចាប់ខ្លួន ឬកម្ទេចកប៉ាល់ថៃ និងវៀតណាម ដោយកងទ័ពជើងទឹក កម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៣០៦-៣២២) ព្រមទាំងវិសាលភាពនៃការទទួលខុសត្រូវរបស់ មាស មុត នៅ (៦) មន្ទីរឃុំឃាំង ៨១០ (កថាខណ្ឌ ៣៣០-៣៥១) និង (៧) នៅក្នុងមន្ទីរសន្តិសុខ កងទ័ពបដិវត្តន៍កម្ពុជា និង ទីតាំងសម្លាប់មនុស្សដទៃទៀត (កថាខណ្ឌ ៣៥២-៣៥៣)។

[76] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១០៨-១២២។

[77] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១២៣-១៣១។

[78] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១៣២-១៣៩។

[79] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១៤០-១៥០។

[80] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១៥១-១៨១, ២០៤- ២២៨។

[81] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ១៨២-២០៣។

[82] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ២២៩-២៤៤។

[83] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ២៤៥-២៥៣។

[84] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ២៥៤-២៥៨។

នយោបាយបក្ស[85] និងជាជំនួយការទីបួននៃគណៈកម្មាធិការមជ្ឈិម សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា មាស មុត មិនមែនជាបុគ្គលម្នាក់នៅក្នុងចំណោមបុគ្គលទាំងដប់បីនាក់ ដែលមានសិទ្ធិចេញបញ្ជាចាប់ខ្លួន និងសម្លាប់ឡើយ[86]។ លោកចៅក្រមយល់ថា បើយោងតាមរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា តួនាទីរបស់ មាស មុត គឺនៅក្រោមកម្មាភិបាលផ្សេងៗប្រហែល ៥០ នាក់ ហើយមានតួនាទីដូចគ្នានឹងកម្មាភិបាលដទៃជាច្រើន ដូចជាលេខាភូមិភាគ និងលេខាកងពលធំ[87]។ លោកចៅក្រមបានបន្ថែមថា ក្នុងនាមជាកម្មាភិបាលមួយរូប មាស មុត មានកាតព្វកិច្ចត្រូវគោរពតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយត្រូវផ្សព្វផ្សាយគោលនយោបាយបក្ស និងសម្របសម្រួលលើការចាប់ខ្លួន និងការបញ្ជូនអ្នកទោសតាមការបញ្ជារបស់ថ្នាក់លើ ហើយការមិនធ្វើតាមបញ្ជា នឹងធ្វើឱ្យគាត់ត្រូវបានគេចាត់ទុកថាជាជនក្បត់ ហើយត្រូវកម្ទេចចោល[88]។ សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា មាស មុត បានចូលរួមក្នុងការទប់ស្កាត់ខ្មាំងពីខាងក្នុង ប៉ុន្តែបានចោទជាសំណួរថាតើ ភស្តុតាងបានបង្ហាញដែរឬទេ អំពីការផ្តួចផ្តើម និងសិទ្ធិអំណាចរបស់ មាស មុត ក្នុងការបញ្ជាចាប់ខ្លួន បញ្ជូន ឬសម្លាប់នរណាម្នាក់ ដោយលោកចៅក្រមបានកត់សម្គាល់ថា កងពលធំ ១៦៤ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ សុន សេន[89]។ លោកចៅក្រមបានពិចារណាបន្ថែមថា ភស្តុតាងដែលប្រមូលបានមិនបានគាំទ្រដល់ចំនួនជនរងគ្រោះស្លាប់ ដូចបានលើកឡើងក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះទេ[90]។

ចំពោះលក្ខណវិនិច្ឆ័យដែលបានចែងអំពីយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតជាតិបានសម្រេចថា យុត្តាធិការរបស់ អ.វ.ត.ក គឺកម្រិតត្រឹមតែថ្នាក់ដឹកនាំមួយចំនួនតូចប៉ុណ្ណោះ[91] ដោយពិចារណាទៅលើច្បាប់ និងយុត្តិសាស្ត្រជាធរមាន ទាក់ទងនឹងយុត្តាធិការបុគ្គល[92] គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀត ទៅលើច្បាប់ព្រហ្មទណ្ឌ

[85] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤១៦។

[86] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤១៨។

[87] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤១៩។

[88] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤២០។

[89] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤២២-៤២៥។

[90] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤២៦។

[91] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៩៥, ៣៩៧។

[92] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៦១-៣៧៦។

ដែលបានទទួលស្គាល់ផងដែរដោយរដ្ឋធម្មនុញ្ញកម្ពុជា[93] ប្រព័ន្ធនៃការធ្វើការសម្រេចដែលមានអត្ថិភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[94] និងចេតនាពិតប្រាកដរបស់ភាគីចរចានៃកិច្ចព្រមព្រៀង និងអ្នកតាក់តែងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលទទួលស្គាល់ថា អ.វ.ត.ក មានយុត្តាធិការកម្រិតកំណត់មួយ[95]។

បន្ទាប់ពីការវិភាគអង្គហេតុ និងអង្គច្បាប់រួចហើយ សហចៅក្រមស៊ើបអង្កេតជាតិបានសន្និដ្ឋានថា មាស មុត ទោះបីជាមានតួនាទីជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្ដី ប៉ុន្តែមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឡើយ[96]។ លោកចៅក្រមបានសម្រេចថា មាស មុត មិនស្ថិតក្នុងប្រភេទនៃមេដឹកនាំជាន់ខ្ពស់ ព្រោះគាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍បក្សឡើយ[97]។ លោកចៅក្រមបានសម្រេចទៀតថា ប្រភេទនៃអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត គ្របដណ្ដប់ត្រឹមតែមនុស្សជាក់លាក់ប៉ុណ្ណោះ ដូចជា កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាដើម[98] ហើយលោកចៅក្រមបានសន្និដ្ឋានថា មាស មុត មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូបឡើយ ព្រោះ "ការចូលរួមរបស់គាត់មិនសកម្ម មិនដុំកំភួន និងមិនបានកៀតកិតនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ"[99]។ ដូច្នេះហើយ សហចៅក្រមស៊ើបអង្កេតជាតិបានច្រានចោលការចោទប្រកាន់ប្រឆាំងនឹង មាស មុត[100]។

## V- និដ្ឋភាពទូទៅនៃកិច្ចដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍ និងបញ្ហានានាដែលបានលើកឡើង

អង្គបុរេជំនុំជម្រះបានទទួលបណ្ដឹងឧទ្ធរណ៍ចំនួនបី ទាក់ទងដីកាដំណោះស្រាយ ដែលបានចេញក្នុងសំណុំរឿងនេះ។ សហព្រះរាជអាជ្ញាជាតិ[101] និង មាស មុត[102] បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ និងថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកា

[93] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៧៧-៣៨៥។

[94] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៨៦-៣៨៩។

[95] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៦១-៣៦៥, ៣៦៨-៣៧៦, ៤០៥-៤០៧។

[96] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤២៩។

[97] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៩៥។

[98] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៣៩០-៣៩៧, ៤០៥។

[99] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤២៨។

[100] ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) (ឯកសារ D266) កថាខណ្ឌ ៤៣០។

សម្រេចលើកលែងចោទប្រកាន់) នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩[103]។ មាស មុត និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបនៅថ្ងៃទី១៤[104] ថ្ងៃទី២៤[105] និងថ្ងៃទី២៨[106] ខែមិថុនា ឆ្នាំ២០១៩ ហើយពួកគាត់បានដាក់ការឆ្លើយតបនៅថ្ងៃទី១៦[107] និងថ្ងៃទី១៩[108] ខែសីហា ឆ្នាំ២០១៩។

ទោះបីជាភាគីនឹងបង្ហាញទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់ពួកគេដោយលម្អិត នៅក្នុងសវនាការ *អសាធារណ:* ក្តី តែអង្គជំនុំជម្រះយល់ថា មានភាពចាំបាច់ និងជាផលប្រយោជន៍នៃតម្លាភាព ដែលនាពេលនេះ ត្រូវផ្តល់សេចក្តីសង្ខេបខ្លីនៃបញ្ហាដែលបានលើកឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ។ ដោយសារតែពេលវេលាមានកំណត់ ទើបលើកយកតែទឡ្ហីករណ៍ចម្បងនៃបណ្តឹងឧទ្ធរណ៍ មកធ្វើការសង្ខេបតែប៉ុណ្ណោះ ដោយមិនសង្ខេបទៅលើទឡ្ហីករណ៍របស់ចម្លើយតប និងការឆ្លើយតបឡើយ។

---

[101] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៣ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3 ("បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3)")។

[102] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4)")។

[103] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266) ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2)")។

[104] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/9។

[105] សំណុំរឿង ០០៣ ចម្លើយរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើកលែងចោទប្រកាន់ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D266/5។

[106] សំណុំរឿង ០០៣ ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D267) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/10។

[107] សំណុំរឿង ០០៣ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ និងដាក់ចូលក្នុងសំណុំរឿង ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ D267/11។

[108] សំណុំរឿង ០០៣ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D266/7។

### ក. បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)

មាស មុត បានលើកឡើងថា បញ្ហាដែលធំទូលាយនៅក្នុងសំណុំរឿងនេះ គឺថាតើដីកាដំណោះស្រាយដែលផ្ទុយគ្នាណាមួយ ដែលមានអាទិភាពជាង រវាងដីកាសម្រេចលើកលែងចោទប្រកាន់ និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[109]។ មាស មុត បានលើកយកមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ចំនួនពីរ ថា ក្នុងករណីដែលមានដីកាដំណោះស្រាយពីផ្ទុយគ្នា និងចេញក្នុងពេលដំណាលគ្នា បានលើកបញ្ហានៃយុត្តាធិការទៅលើជនត្រូវចោទ ដោយមានទម្ងន់ដូចគ្នានោះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចត្រូវតម្កល់បានឡើយ ហើយការជំនុំជម្រះមិនបានបន្តដំណើរការទេ នៅក្រោមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ឡើយ[110]។

មាស មុត បានជំទាស់ជាពិសេស នៅក្នុងមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់គាត់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ដោយបកស្រាយនៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់គាត់ពីវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង ក្នុងលក្ខណៈមួយដែលថា ប្រសិនបើអង្គបុរេជំនុំជម្រះ មិនអាចសម្រេចតម្កល់ដីកាដំណោះស្រាយណាមួយ ដោយសម្លេងភាគច្រើនលើសលប់ទេ ដីកាដំណោះស្រាយទាំងពីរ ឬដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់ មានអានុភាពអនុវត្ត[111]។

នៅក្នុងមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់គាត់ មាស មុត បានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ ដោយមិនបានសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់គាត់ដែលថា ប្រសិនបើអង្គបុរេជំនុំជម្រះមិនអាចសម្រេចដោយសម្លេងភាគច្រើន

[109] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4) ទំព័រ ១។

[110] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4) ទំព័រ ១។

[111] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4) កថាខណ្ឌ ៣២ -៤៨។ ដើម្បីគាំទ្រដល់មូលដ្ឋាននេះ គាត់បានលើកទឡ្ហីករណ៍ថា (១) ភាគីនៃកិច្ចព្រមព្រៀង មិនមានចេតនាឲ្យសំណុំរឿងមួយ ត្រូវបន្តកិច្ចដំណើរការនីតិវិធីទៅដំណាក់កាលជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ក្នុងករណីមានដីកាសម្រេចលើកលែងចោទប្រកាន់ ដែលបានចេញក្នុងពេលជាមួយគ្នា(កថាខណ្ឌ ៣៣-៤០, ៤៧-៤៨) និង (២) ការអនុវត្តវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដើម្បីប្តឹងឧទ្ធរណ៍ដីកាដំណោះស្រាយដែលផ្ទុយ នឹងនាំឲ្យមានលទ្ធផលមួយដែលមិនសមហេតុផល បណ្តាលឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់គាត់ ហើយនឹងរំលោភបំពានទៅលើរដ្ឋធម្មនុញ្ញកម្ពុជា និងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (កថាខណ្ឌ ៤១-៤៦, ៤៧-៤៨)។

លើសលប់ថា សហចៅក្រមស៊ើបអង្កេតជាតិ បានប្រព្រឹត្តកំហុស ឬការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋាននៃការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់គាត់ទេនោះ ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានអនុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយអនុលោមតាមគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[112]។

ដោយផ្អែកលើមូលដ្ឋាននេះ មាស មុត ស្នើដល់អង្គបុរេជំនុំជម្រះឱ្យច្រានចោលសំណុំរឿងប្រឆាំងនឹងរូបគាត់[113]។

## ខ. បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)

នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ សហព្រះរាជអាជ្ញាជាតិ បានស្នើដល់អង្គបុរេជំនុំជម្រះ ឱ្យច្រានចោលសំណុំរឿងប្រឆាំង មាស មុត ដោយផ្អែកលើទស្សនៈរបស់គាត់ដែលថា មាស មុត មិនមានការទទួលខុសត្រូវ ហើយមិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ[114]។

ចំពោះចំណុចទីមួយរបស់គាត់ សហព្រះរាជអាជ្ញាជាតិបានសង្កត់ធ្ងន់ថា ការបោសសម្អាតនៅកម្រិតភូមិភាគ ត្រូវសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការងារដឹកនាំប្រចាំថ្ងៃ ជំនួសគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា[115]។ សហព្រះរាជអាជ្ញាជាតិបានបន្ថែមថា គោលនយោបាយបង្គ្រាប ដែលតម្រូវឱ្យកម្មាភិបាលត្រូវគោរពតាម បើមិនដូច្នេះទេនឹងត្រូវបោស

---

[112] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4) កថាខណ្ឌ ៤៩-៦៦។ ដើម្បីគាំទ្រដល់មូលដ្ឋាននេះ គាត់បានជំទាស់ *ក្នុងចំណោមប្រការផ្សេងទៀត* ថា (១) គោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវថា វិមតិសង្ស័យ ទាំងចំពោះអង្គហេតុ និងការបកស្រាយ បទប្បញ្ញត្តិគតិយុត្តិ ចាំបាច់ត្រូវតែដោះស្រាយ ជាប្រយោជន៍ដល់ជនជាប់ចោទ (កថាខណ្ឌ ៥០-៥១, ៦៦) និង (២) បើមិនមានកំហុស ឬការរំលោភបំពានលើឆន្ទានុសិទ្ធិ ដែលប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេតជាតិ នៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) របស់គាត់ ដែលនាំឱ្យមានការរារាំងការអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* ទេនោះ ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវតែមានអានុភាពអនុវត្ត (កថាខណ្ឌ ៥២-៦៥, ៦៦)។

[113] បណ្តឹងឧទ្ធរណ៍របស់ មាស មុត (ឯកសារ D267/4) កថាខណ្ឌ ៦៧-៧២ ទំព័រ ៤៦។

[114] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៥៦-៦០, ៦១-៧៤។

[115] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៥៦-៥៨។

សម្អាតនោះ គ្របដណ្តប់ទូទាំងប្រទេស ជាពិសេសក្នុងឆ្នាំ១៩៧៦[116]។

ចំពោះចំណុចទីពីររបស់គាត់ សហព្រះរាជអាជ្ញាជាតិបានលើកទឡ្ហីករណ៍ថា រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាភាគីមួយដែលបង្កើត អ.វ.ត.ក អាចមានឥទ្ធិពលទៅលើដំណើរការនៃវិសាលភាពយុត្តាធិការបុគ្គល និងកិច្ចការរបស់តុលាការ"[117] និងការបញ្ចប់អាណត្តិការងាររបស់ អ.វ.ត.ក រួមទាំងការកម្រិតកំណត់ទៅលើវិសាលភាពនៃយុត្តាធិការបុគ្គល ដូចគ្នានឹងករណីនៅតុលាការ ICTY, ICTR និងតុលាការ SCSL ដែរ[118]។ ដោយផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាជាតិ "បានទទួចដល់អង្គបុរេជំនុំជម្រះ ឱ្យបំពេញការងារស្របទៅតាម"[119] ការបកស្រាយរបស់រដ្ឋាភិបាលដែលថា ច្បាប់ជាធរមានតម្រូវឱ្យ អ.វ.ត.ក ធ្វើការស៊ើបអង្កេត និងជំនុំជម្រះ តែទៅលើមេដឹកនាំជាន់ខ្ពស់ ដែលគេយល់ថាគ្របដណ្តប់តែទៅលើ បុគ្គលមួយចំនួនតូចដែលជា សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ដែលគេយល់ថាសំដៅតែទៅលើ កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរសន្តិសុខ ស-២១[120]។ សហព្រះរាជអាជ្ញាជាតិបានលើកឡើងបន្ថែមទៀតថា យុត្តិធម៌ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការជំនុំជម្រះក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ រួចហើយ[121]។

សហព្រះរាជអាជ្ញាជាតិបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យច្រានចោលសំណុំរឿងប្រឆាំងនឹង មាស មុត ដោយផ្អែកលើមូលដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើរូបគាត់ឡើយ[122]។

### គ. បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)

នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកមូលដ្ឋានចំនួនប្រាំបី ដែល

---

[116] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៥៩-៦០។

[117] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៦៧។សូមមើល ផងដែរ កថាខណ្ឌ ៦១-៦៧។

[118] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៦៣។ សូមមើល ផងដែរ កថាខណ្ឌ ៦១-៦៧។

[119] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៦៧។

[120] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៦៨។ សូមមើលផងដែរ កថាខណ្ឌ ៦៧, ៦៩-៧៣។

[121] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៧៣។

[122] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3) កថាខណ្ឌ ៧៥។

ថាដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសារបានសន្និដ្ឋានសម្រេចថា មាស មុត មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក[123]។

ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ ដោយមិនបានសម្រេចលើអង្គហេតុ និងអង្គច្បាប់ ទាក់ទងនឹងបញ្ហាថាតើឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តដែរឬទេ និងថាតើ មាស មុត ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរឬយ៉ាងណាចំពោះឧក្រិដ្ឋកម្មទាំងនោះ[124]។

ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ ដោយសារមិនបានពិចារណាទៅលើភស្តុតាងនានាដែលបានដាក់ក្នុងសំណុំរឿង បន្ទាប់ពីការចេញសេចក្តីជូនដំណឹងលើកទីមួយ ស្តីពីការបញ្ចប់កិច្ចស៊ើបសួរ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ចំណុចនេះពាក់ព័ន្ធទាំងចំពោះភស្តុតាងដែលបានប្រមូលក្រោយកាលបរិច្ឆេទនោះ និងសម្ភារៈដែលបានបង្កើតឡើងពីពេលមុន ប៉ុន្តែមិនទាន់ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅពេលនោះ[125]។

ទីបី សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ដោយសារមិនបានពិចារណា និងមិនបានចេញសេចក្តីសម្រេច ទៅលើអង្គហេតុទាំងអស់ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០៣ ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[126]។

ទីបួន សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការពិចារណាទៅលើការបង្ខំ ការគាបសង្កត់ និងបញ្ជារបស់ថ្នាក់លើ នៅពេលសម្រេចលើកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត[127]។

ទីប្រាំ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែង

---

123 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ២, ១៩-១៩០។

124 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ២០-៣៤។

125 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ៣៥-៦២។

126 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ៦៣-៨២។

127 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ៨៣-១១១។

ចោទប្រកាន់) មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការពិចារណារបស់ខ្លួនទៅលើការចូលរួមផ្ទាល់ និងភាពកៀកកិតជាមួយឧក្រិដ្ឋកម្ម នៅពេលសម្រេចពីកម្រិតនៃការទទួលខុសត្រូវរបស់ មាស មុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត[128]។

ទីប្រាំមួយ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) បានសម្រេចលើអង្គហេតុ ដែលមានកំហុសជាច្រើន លើចំណុចដែលសំខាន់ក្នុងការវាយតម្លៃលើបញ្ហា ថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា[129]។

ទីប្រាំពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកទឡ្ហីករណ៍ថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ ក្នុងការពិចារណាទៅលើជនរងគ្រោះ[130]។

ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) មានកំហុសអង្គច្បាប់ ដោយបកស្រាយថា ការកម្រិតកំណត់យុត្តាធិការ ដែលកម្រិតដោយប្រភេទ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អាចអនុវត្តបានតែចំពោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច តែប៉ុណ្ណោះ[131]។

សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងបន្ថែមទៀតថា ក្នុងករណីដែលអង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងភាគច្រើនលើសលប់សម្រាប់សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬច្រានចោលបណ្តឹងឧទ្ធរណ៍ទាំងអស់នេះបានទេនោះ សំណុំរឿងនេះត្រូវបន្តទៅជំនុំជម្រះ ដោយផ្អែកលើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[132]។

ផ្អែកលើសំអាងហេតុទាំងអស់នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំដំណោះស្រាយថា អង្គបុរេជំនុំជម្រះច្រានចោលដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់) ហើយសម្រេចថា មាស មុត ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត និងបញ្ជូន មាស មុត ទៅជំនុំជម្រះ ផ្អែកលើដីកា

---

128 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ១១២ -១៣៤។

129 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ១៣៥ -១៥៤។

130 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ១៥៥ -១៧០។

131 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ១៧១ -១៨០។

132 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ១៨១ -១៨៤។

ដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[133]។

## VI- សេចក្តីសន្និដ្ឋាន

អង្គបុរេជំនុំជម្រះបានផ្តល់របាយការណ៍សង្ខេបស្តីពីសំណុំរឿងនេះ និងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នាពេលបច្ចុប្បន្ន ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងតម្លាភាព ប៉ុន្តែទទួលស្គាល់គោលការណ៍រក្សាការសម្ងាត់នៅដំណាក់កាលមុនជំនុំជម្រះ។ របាយការណ៍នេះនឹងត្រូវដាក់ចូលទៅក្នុងសំណុំរឿង ហើយផ្សព្វផ្សាយជូនសាធារណជននៅលើគេហទំព័ររបស់ អ.វ.ត.ក។

ភ្នំពេញថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

[133] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ D266/2) កថាខណ្ឌ ៣, ២០៣។ សូមមើលផងដែរ កថាខណ្ឌ ១៩៩ -២០២។